ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៥០០ ១៧៥ . ឧថ . ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពីការបង្កើតគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ និង ប្រគល់កិច្ចសន្យា (PEACs) របស់ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

---

## រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ កក្កដា ឆ្នាំ១៩៩៥ របស់រាជរដ្ឋាភិបាលស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ

- បានឃើញសារាចរណែនាំលេខ ០០៦ សណន.សហវ.សក ចុះថ្ងៃទី១១ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ របស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការអនុវត្តនីតិវិធាន និង បទប្បញ្ញត្តិក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១:** បង្កើតគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃនិងប្រគល់កិច្ចសន្យា (PEACs) ដែលមានសមាសភាពដូចតទៅ៖

| | | | |
|---|---|---|---|
| ១_ឯកឧត្តម | **ញ៉ឹក ច្រឹង** | រដ្ឋលេខាធិការ | ប្រធាន |
| ២_ឯកឧត្តម | **ខួន នៅ** | អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម | អនុប្រធាន |
| ៣_លោក | **អ៊ិច ម៉ូរ៉ា** | អគ្គនាយករងនៃ នៃអគ្គនាយកដ្ឋានធនធានរ៉ែ | អនុប្រធាន |
| ៤_លោក | **សាត សមុទ្រ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានឧស្សាហកម្ម | សមាជិក |
| ៥_លោក | **អ៊ិន ពៅ** | ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៦_លោក | **ញ៉ឹក អឿត** | អនុប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ | សមាជិក |
| ៧_លោក | **ឡុង សុគន្ធា** | អនុប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ | សមាជិក |
| ៨_លោក | **ចី ពិទូរ្យ** | អនុប្រធាននាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម | សមាជិក |
| ៩_លោក | **ច្រាក់ ចំនួនរ័ត្ន** | ប្រធានការិយាល័យលទ្ធកម្ម និង ជាលេខាកត់ត្រា | |

**ប្រការ២:** គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និង ប្រគល់កិច្ចសន្យា (PEACs) មានភារកិច្ច ៖

១_តែងតាំងក្រុមវាយតម្លៃបច្ចេកទេសដែលត្រូវបំពេញតួនាទីពាក់ព័ន្ធនិងការដេញថ្លៃដូចខាងក្រោម៖

- បើកសំណើដេញថ្លៃនិងរៀបចំរបាយការណ៍ទៅ PEAC
- វាយតម្លៃបច្ចេកទេសលើសំណើដេញថ្លៃទាំងឡាយ ហើយរៀបចំរបាយការណ៍នេះទៅ PEAC ។

ក្រុមវាយតម្លៃបច្ចេកទេស ត្រូវមានសមាសភាពបុគ្គលិកដែលមានជំនាញបច្ចេកទេសសមស្របនិងដឹកនាំដោយប្រធានការិយាល័យលទ្ធកម្ម ។

២_ពិនិត្យរបាយការណ៍ស្តីពីការបើកសំណើដេញថ្លៃ និង របាយការណ៍វាយតម្លៃបច្ចេកទេសដែលផ្តល់ដោយក្រុមវាយតម្លៃបច្ចេកទេស ព្រមទាំងលើកសំណើប្រគល់កិច្ចសន្យា ជូនឯកឧត្តមរដ្ឋមន្ត្រី ដើម្បីពិនិត្យ និង សម្រេច ។

៣_ ក្នុងកិច្ចសន្យាដែលធ្វើឡើងក្រៅពីរូបភាពដេញថ្លៃដោយប្រកួតប្រជែង ដូចជា៖ ពិគ្រោះថ្លៃ ស្ពង់តម្លៃ ក្នុងស្រុកការទិញ ឬ ចុះកិច្ចសន្យាដោយផ្ទាល់ តាមរយៈការប្រគល់សិទ្ធិដោយឯកឧត្តមរដ្ឋមន្ត្រីនោះប្រធាន PEAC អាចមានសិទ្ធិសម្រេចប្រគល់កិច្ចសន្យាលើកិច្ចលទ្ធកម្មនេះបាន ។

៤_ តាមរយៈការប្រទានសិទ្ធិពីឯកឧត្តមរដ្ឋមន្ត្រី ប្រធាន PEAC អាចអនុម័ត និង ចុះហត្ថលេខាជំនួស លើកិច្ចសន្យាលទ្ធកម្មក្នុងនាមឯកឧត្តមរដ្ឋមន្ត្រី ។

៥_ ប្រធាន PEAC អាចសម្រេចលើការអនុវត្តន៍កិច្ចសន្យាលទ្ធកម្ម

**ប្រការ៣:** គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និង ប្រគល់កិច្ចសន្យា (PEACs) របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដូចមានចែងក្នុងប្រការ១ ត្រូវដាក់ពាក់ឯកសារជូនឯកឧត្តមរដ្ឋមន្ត្រីសម្រេចជាចុងក្រោយ ។

**ប្រការ៤:** អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានគ្រប់នាយកដ្ឋាន និងសាមីជនដូចក្នុងប្រការ១ មានភារកិច្ចអនុវត្តក្នុងក្របខណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

**ប្រការ៥:** បទប្បញ្ញត្តិនិងសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍

**ប្រការ៦:** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ_សែម

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  ( ដើម្បីជូនជ្រាប )
- ដូចប្រការ ៥ ( ដើម្បីអនុវត្ត )
- ឯកសារ កាលប្បវត្តិ